**សលាកប័ត្រព័ត៌មាន៖** កម្រងស្ថាប័ន៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ស្ថាប័ន៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទិដ្ឋភាពរួម៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានបង្កើតឡើងនៅក្នុងខែឧសភា ឆ្នាំ២០០៣ ជាស្ថាប័នជាតិឯករាជ្យ ដែលមានអំណាចផ្លូវច្បាប់ទទួលខុសត្រូវក្នុងការដោះស្រាយវិវាទការងាររួម តាមរយៈការផ្សះផ្សា និងមជ្ឈត្តកម្ម។

## សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ ផ្តល់នូវទិដ្ឋភាពទូទៅអំពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ("ក្រសួងការងារ") និយោជក និងសហជីព ក៏ដូចជាមានការជួយជ្រោមជ្រែងពីអង្គការពលកម្មអន្តរជាតិ ("អាយឡូ") ដោយមានគោលបំណងផ្តល់នូវប្រព័ន្ធសម្រាប់ដោះស្រាយវិវាទការងាររួមប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។ សលាកប័ត្រនេះ តាក់តែងឡើងដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ("អង្គការ") ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

## ប្រវត្តិរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

នៅក្នុងឆ្នាំ២០០២ អង្គការពលកម្មអន្តរជាតិ បានចាប់ផ្តើមអនុវត្តគម្រោងដោះស្រាយវិវាទការងាររបស់ខ្លួននៅកម្ពុជា ដោយផ្តល់ជំនួយផ្នែកបច្ចេកទេសដល់ក្រសួងការងារ។ ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងពីប្រព័ន្ធដ៏ទូលំទូលាយសម្រាប់ធ្វើការដោះស្រាយវិវាទការងារ។ តែយ៉ាងណាក៏ដោយ កម្រិតដ៏ខ្ពស់នៃអំពើពុករលួយ និងកង្វះតម្លាភាពនៅក្នុងការគ្រប់គ្រងរដ្ឋបាលការងារ និងតុលាការ បានរឹតត្បិតជាខ្លាំងដល់ប្រសិទ្ធភាពរបស់ប្រព័ន្ធដោះស្រាយវិវាទការងារនេះ។ ដើម្បីដោះស្រាយនូវកង្វះយន្តការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាពនេះ អង្គការពលកម្មអន្តរជាតិបានផ្តួចផ្តើមបង្កើតក្រុមប្រឹក្សាអាជ្ញាកណ្តាល បន្ទាប់ពីបានធ្វើការវាយតម្លៃ និងធ្វើការប្រឹក្សាយោបល់ជាច្រើនជាមួយដៃគូ និងស្ថាប័នពាក់ព័ន្ធនានា។ បន្ទាប់ពីមានការចរចាជាច្រើនខែដោយអនុលោមតាមមាត្រា ៣១៧ នៃច្បាប់ស្តីពីការងារ លទ្ធផលចុងក្រោយ ក្រសួងការងារបានបង្កើតក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមរយៈការចេញប្រកាសលេខ ៣៣៨ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងខែធ្នូ ឆ្នាំ២០០២ ក្រោយមកក៏ជំនួសដោយ ប្រកាសលេខ ៩៩ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងខែមេសា ឆ្នាំ២០០៤ ("ប្រកាសលេខ ៩៩")។ នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចាប់ផ្តើមដំណើរការ។

## មុខងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ដំណើរការសវនាការរបស់អាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺជាយន្តការដោះស្រាយវិវាទរួមក្រៅប្រព័ន្ធ ដែលត្រូវបានបង្កើតឡើងដើម្បីដោះស្រាយវិវាទការងារនៅកម្ពុជា។ នៅពេលវិវាទការងាររួមមួយកើតឡើង ដំបូងឡើយ ក្រសួងការងារនឹង

ព្យាយាមដើម្បីដោះស្រាយវិវាទនោះតាមរយៈការផ្សះផ្សា។ ក្នុងករណីពុំមានការព្រមព្រៀងគ្នារវាងភាគីទាំងអស់ទេនោះ អ្នកផ្សះផ្សាវិវាទរបស់ក្រសួងការងារធ្វើរបាយការណ៍អំពីការមិនសះជា។ យោងតាមមាត្រា ៣០៩ និងមាត្រា ៣១០ នៃច្បាប់ស្ដីពីការងារ ក្នុងករណីពុំមានអនុសញ្ញារួម ឬនីតិវិធីណាផ្សេងទៀតដែលយល់ព្រមដោយភាគីទេនោះ ក្រសួងការងារនឹងបញ្ជូនវិវាទនោះទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងរយៈពេលបីថ្ងៃ។

បច្ចុប្បន្ននេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានសមាជិកចំនួន ៣០ រូប ដែលត្រូវបានតែងតាំង ឬជ្រើសតាំងដោយប្រកាសរបស់ក្រសួងការងារជារៀងរាល់ឆ្នាំ។ ដើម្បីធានាតម្លាភាព និងឯករាជ្យភាព អាជ្ញាកណ្ដាលទាំងអស់ត្រូវជ្រើសតាំងដោយមានចំនួនស្មើភាពគ្នាពីក្រុមនីមួយៗក្នុងចំណោមភាគីពាក់ព័ន្ធចំនួនបី រួមមាន៖ សហជីព សមាគមនិយោជក និងក្រសួងការងារ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលការគាំទ្រពីលេខាធិការដ្ឋានដែលទទួលខុសត្រូវកិច្ចការផ្នែករដ្ឋបាល និងការចុះបញ្ជី ហើយដែលមានសមាសភាពមន្ត្រីក្រសួងដែលត្រូវធ្វើការជាមួយគ្នានៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

យោងតាមប្រការទី១២ នៃប្រកាសលេខ ៩៩ វិវាទរួមដែលបានបញ្ជូនទៅកាន់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងត្រូវដោះស្រាយដោយក្រុមអាជ្ញាកណ្ដាល។ ក្រុមអាជ្ញាកណ្ដាលមានសមាសភាពចំនួនបីរូប។ ភាគីវិវាទនីមួយៗ មានសិទ្ធិជ្រើសរើសអាជ្ញាកណ្ដាលមួយរូបមកពីក្រុមតំណាងរបស់ខ្លួន ដែលអាជ្ញាកណ្ដាលទាំងពីរនេះក្រោយមកនឹងជ្រើសរើសអាជ្ញាកណ្ដាលចុងក្រោយមកពីក្រុមបេក្ខជនរបស់ក្រសួងការងារ។ ភាគីនានាអាចចូលខ្លួនបង្ហាញនៅចំពោះក្រុមអាជ្ញាកណ្ដាលដោយផ្ទាល់ ប៉ុន្តែក៏អាចមានមេធាវីតំណាង ឬបុគ្គលជាតំណាងដទៃផ្សេងទៀត ដែលភាគីនោះបញ្ជាក់ពីការផ្ដល់សិទ្ធិទៅឲ្យ។ ក្រុមអាជ្ញាកណ្ដាលស្ដាប់ការអះអាង និងទឡ្ហីករណ៍របស់ភាគីនានា និងធ្វើការពិនិត្យលើសាក្សី ឬឯកសារនានាដែលពាក់ព័ន្ធនឹងវិវាទ។ យុត្តាធិការរបស់ក្រុមអាជ្ញាកណ្ដាលត្រូវបានកំណត់ត្រឹមតែការដោះស្រាយបញ្ហាដែលមាននៅក្នុងរបាយការណ៍មិនសះជា រួមទាំងបញ្ហានានាដែលជាផលវិបាកផ្ទាល់នៃវិវាទនោះ ប៉ុន្តែត្រូវតែជាបញ្ហាដែលកើតឡើងពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នោះតែប៉ុណ្ណោះ។

ដូចមានចែងនៅក្នុងប្រការទី២០ នៃប្រកាសលេខ ៩៩ ក្នុងអំឡុងពេលដំណើរការរបស់អាជ្ញាកណ្ដាល ភាគីនានាត្រូវតែជៀសវាងការធ្វើកូដកម្ម ឡុកអៅ ឬសកម្មភាពផ្សេងៗ ដែលអាចធ្វើឲ្យវិវាទរវាងភាគីកាន់តែធ្ងន់ធ្ងរ។ ប្រសិនបើកូដកម្ម ឬឡុកអៅ ត្រូវមានអានុភាពអនុវត្តនៅពេលនៃដំណើរការរបស់អាជ្ញាកណ្ដាល ក្រុមអាជ្ញាកណ្ដាលអាចចេញសេចក្ដីបង្គាប់បណ្ដោះអាសន្ន ដោយបញ្ជាឲ្យបញ្ឈប់នូវសកម្មភាពនោះដើម្បីឲ្យក្រុមអាជ្ញាកណ្ដាលអាចដំណើរការនីតិវិធីបាន។

**សេចក្ដីបង្គាប់របស់អាជ្ញាកណ្ដាល**

តាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារចែងថា ក្រុមអាជ្ញាកណ្ដាលត្រូវចេញនូវសេចក្ដីសម្រេចរបស់ខ្លួនក្នុងទម្រង់នៃសេចក្ដីបង្គាប់របស់អាជ្ញាកណ្ដាល ហើយបញ្ជូនទៅក្រសួងការងារក្នុងរយៈពេល ១៥ ថ្ងៃ។ សេចក្ដីបង្គាប់ទាំងអស់អាចស្វែងរកបានជាសាធារណៈនៅលើគេហទំព័ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទាំងភាសាខ្មែរ និងភាសាអង់គ្លេស។ អាជ្ញាកណ្ដាលត្រូវបានរំពឹងថានឹងធ្វើសេចក្ដីសម្រេចជាឯកច្ឆន្ទ តែយ៉ាងណាក្ដី នៅពេល

ដែលករណីនេះមិនអាចទៅរួច នឹងសម្រេចយកតាមសំឡេងភាគច្រើន។ សេចក្តីបង្គាប់របស់អាជ្ញាកណ្តាលអាចមានការចងភ្ជាប់សេចក្តីបង្គាប់ក្នុងការដោះស្រាយវិវាទការងាររួម តាមរយៈការបង្គាប់ឲ្យនិយោជិតដែលត្រូវបណ្តេញចេញពីការងារចូលបម្រើការងារវិញ ដោយសងភ្លាមនូវចំនួនទឹកប្រាក់ដែលនិយោជកជំពាក់ទៅឲ្យកម្មករវិញ ការបញ្ឈប់នូវសកម្មភាពឧស្សាហកម្មណាមួយ ឬការប្រព្រឹត្តអំពើពុំស្របច្បាប់ដទៃៗទៀតជាដើម។ តែយ៉ាងណាក្តី បន្ទាប់ពីភាគីវិវាទ ត្រូវបានជូនដំណឹងពីការចេញសេចក្តីបង្គាប់របស់អាជ្ញាកណ្តាល ភាគីនីមួយៗមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចនោះតាមរយៈលេខាធិការដ្ឋាន នៅក្នុងរយៈពេលប្រាំបីថ្ងៃនៃថ្ងៃប្រតិទិន។ ការជំទាស់ទាន់ពេលវេលាមានន័យថា សេចក្តីបង្គាប់នោះមិនអាចអនុវត្តបានទេ ហើយវិវាទនោះនឹងត្រូវបញ្ជូនទៅតុលាការដើម្បីសម្រេចចុងក្រោយ។ ផ្ទុយទៅវិញ ប្រសិនបើភាគីមិនជំទាស់នឹងសេចក្តីបង្គាប់ទេនោះ សេចក្តីបង្គាប់របស់អាជ្ញាកណ្តាលគឺជាសេចក្តីសម្រេចចុងក្រោយនិងចងកាតព្វកិច្ចផ្លូវច្បាប់សម្រាប់ភាគីពាក់ព័ន្ធទាំងពីរត្រូវគោរពតាម។

**សេចក្តីសន្និដ្ឋាន**

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានគេចាត់ទុកថា ជាស្ថាប័នមួយប្រកបដោយតម្លាភាព និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាស្ថាប័នដែលគួរជាទីទុកចិត្ត។ ចំនួនករណីនៃវិវាទដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានដោះស្រាយប្រចាំឆ្នាំ មានការកើនឡើងគួរឲ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ២០០៣ ដែលនៅឆ្នាំនោះក្រុមប្រឹក្សាអាជ្ញាកណ្តាលបានដោះស្រាយវិវាទត្រឹមតែ ៣១ ករណីប៉ុណ្ណោះ។ ក្នុងឆ្នាំ២០១១ តួលេខនេះបានកើនឡើងដល់ចំនួន ១៨៩ ករណី និងកើនដល់ចំនួន ២៥៥ ករណីនៅក្នុងឆ្នាំ២០១២។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៣នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដោះស្រាយវិវាទចំនួន ២៦៨ ករណីរួចហើយ។ ដោយឡែកពីនេះ នៅក្នុងត្រីមាសទីបីក្នុងឆ្នាំ២០១៣ នេះ (ចាប់ពីខែកក្កដា ដល់ខែកញ្ញា) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចុះបញ្ជីសំណុំរឿងច្រើនបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ដោយមានករណីចំនួន ៨៧ ត្រឹមតែនៅក្នុងរយៈពេលបីខែប៉ុណ្ណោះ ដែលតួលេខនេះមានការកើនឡើងចំនួន ៣០% បើធៀបជាមួយនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១២ និង ៧៧% នៃចំនួនសំណុំរឿងទទួលបាននៅក្នុងឆ្នាំ២០១១។ នេះសបញ្ជាក់ឲ្យឃើញថា ការជឿជាក់ និងទំនុកចិត្តចំពោះស្ថាប័នមួយនេះបន្តកើនឡើងជាលំដាប់ ដែលជាសមិទ្ធផលដ៏ធំធេងនៅកម្ពុជា ដោយធ្វើពិនិត្យពិចារណាចំពោះការបាត់បង់ទំនុកចិត្តជាទូទៅលើប្រព័ន្ធយុត្តិធម៌ក្នុងចំណោមប្រជាពលរដ្ឋខ្មែរ។

យ៉ាងណាក៏ដោយ មានការព្រួយបារម្ភមួយចំនួនពាក់ព័ន្ធទៅនឹងក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាពិសេសចំពោះការមិនគោរពតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងក្នុងករណីដែលស្ថាប័ននេះកង្វះសមត្ថភាពផ្នែកឃ្លាំមើល និងតាមដានការអនុវត្តន៍។ ដរាបណា ភាគីវិវាទមិនសម្រេចថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមានការចងកាតព្វកិច្ចលើភាគីនោះទេ ដរាបនោះ សេចក្តីសម្រេចនេះ នឹងមិនត្រូវបានភាគីអនុវត្តតាម។ តែយ៉ាងណាក្តី សេចក្តីបង្គាប់របស់អាជ្ញាកណ្តាលនឹងចងកាតព្វកិច្ច ក្នុងករណីភាគីមិនធ្វើការជំទាស់ក្នុងរយៈពេលប្រាំបីថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេចនេះ តាមការអនុវត្តន៍ជាក់ស្តែង ពុំមានយន្តការបង្ខំឲ្យភាគីអនុវត្តតាមសេចក្តីសម្រេចនោះទេ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង លោក ឌុច ពិសិដ្ឋ តាមរយៈទូរសព្ទ៖ (០) ១២ ៧១ ២៣ ៧១ ឬអ៊ីម៉ែល៖ duchpiseth@cchrcambodia.org ឬលោកស្រី អ៊ីលីស ទីឡែត តាមរយៈទូរសព្ទ៖ +៨៥៥(០) ៧៧ ៧០ ៩៧ ២៣ ឬអ៊ីម៉ែល៖ elise.tillet@cchrcambodia.org។